ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

លេខៈ ១៤៧/១៦ គលម

**កំណត់ហេតុ**

# កិច្ចប្រជុំពិនិត្យបញ្ចប់សេចក្តីព្រាងនៃកិច្ចព្រមព្រៀងរវាង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែសីហា ថ្ងៃទីម្ភៃបួន ដល់ ថ្ងៃទីម្ភៃប្រាំមួយ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប មានរៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-ចិនលើកទី២ ដើម្បីពិភាក្សាសម្រេចសេចក្តីព្រាងនៃកិច្ចព្រមព្រៀងស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានគណៈប្រតិភូរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងគណៈប្រតិភូរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនដឹកនាំដោយ **លោកឆេន ស៊ីគួ** អគ្គនាយករង នៃអគ្គនាយកដ្ឋានស៊ើបអង្កេត របស់ក្រសួងសន្តិសុខសាធារណៈ ។

សមាសភាពចូលរួមកិច្ចប្រជុំរួមមាន គណៈប្រតិភូរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចំនួន ២៦រូប និង គណៈប្រតិភូរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនចំនួន ១៤រូប ។

**លោកជំទាវ ឃឹម សុភា** អភិបាលរងខេត្តសៀមរាប និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានមានប្រសាសន៍រៀបរាប់ពីស្ថានភាពទូទៅ ហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ចរបស់ខេត្តសៀមរាប ដែលមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ដោយមានកិច្ចសហការពីអាជ្ញាធរខេត្ត និងបណ្តាអង្គការដៃគូមួយចំនួន ដែលបាននិងកំពុងខិតខំយកចិត្តទុកដាក់លើការងារពាក់ព័ន្ធមួយចំនួនដូចជា ការអប់រំ សន្តិសុខសាធារណៈ និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិ ដើម្បីធ្វើការកំណត់ជាអាទិភាពសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយយើងមានមន្ត្រីអនុវត្តន៍ច្បាប់គឺមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកការពារស្ត្រី និងកុមារ ដែលត្រូវបានគេកេងប្រវ័ញ្ចកម្លាំងពលកម្ម និងធ្វើការជួញដូរផ្លូវភេទ ដោយពួកគាត់ត្រូវបានការពារដោយច្បាប់ ហើយយើងនឹងធ្វើការដាក់ទោសទៅលើជនណាដែលបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។ នៅថ្ងៃនេះ នៅខេត្តសៀមរាបបានបើកកិច្ចប្រជុំពិភាក្សាលើខ្លឹមសារការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស សហការដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រសួងមហាផ្ទៃ និងក្រសួងសន្តិសុខសាធារណៈចិន ដើម្បីលើកកម្ពស់ស្ត្រីឲ្យមានភាពល្អប្រសើរជាងមុន មានន័យថាកម្ពុជានិងចិនមានតួនាទីធ្វើការផ្លាស់ប្តូរពលរដ្ឋទិសោធន៍ពីគ្នាទៅវិញទៅមក ទោះបីនៅក្នុងស្ថានភាពណាក៏ដោយ ហើយជាចុងក្រោយនេះសូមឲ្យអង្គប្រជុំមានដំណើរការទៅមុខដោយរលូន និងមានភាពជោគជ័យយ៉ាងត្រចះត្រចង់ ។

មតិស្វាគមន៍របស់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ក្នុងឱកាសបើកកិច្ចប្រជុំពិភាក្សាទ្វេភាគីកម្ពុជា-ចិនលើកទី២៖

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានថ្លែងអំណរគុណចំពោះការមកដល់កម្ពុជានៃគណៈប្រតិភូចិនប្រកបដោយសុវត្ថិភាព តាងនាមឲ្យប្រមុខរាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ។ ប្រទេសចិនសព្វថ្ងៃនេះមានការរីកចម្រើនលើគ្រប់វិស័យជាងគេនៅលើពិភពលោក ទាំងទ្វីបអាស៊ី និងអឺរ៉ុប ដោយមានកំណើនសេដ្ឋកិច្ចរីកចម្រើនគួរឲ្យកត់សម្គាល់ ហើយកម្ពុជាជាប្រទេសធ្លាប់មានចំណងទាក់ទងជាមួយបណ្ដាប្រទេសនៅលើពិភពលោក ជាពិសេសប្រទេសចិន ដោយបានផ្សារភ្ជាប់ចំណងសាមគ្គីភាពក្នុងរយៈកាលកន្លងមកដូចជា ទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម និងទេសចរណ៍ជាដើម ហើយប្រជាជនប្រទេសទាំងពីរមានទំនាក់ទំនងល្អជាមួយគ្នាយ៉ាងស្អិតរមួត ដែលទន្ទឹមនឹងនោះក៏លេចចេញនូវបញ្ហាការជួញដូរមនុស្ស ដែលមានមេខ្យល់ជាអ្នកបោកបញ្ឆោតស្ត្រីខ្មែរទៅរៀបការប្ដីជាជនជាតិចិន ហើយត្រូវបានគេរកឃើញជនរងគ្រោះជាបន្តបន្ទាប់ ទាំងស្របច្បាប់ និងខុសច្បាប់ ដែលជាកង្វល់យ៉ាងខ្លាំងដល់រដ្ឋាភិបាលប្រទេសទាំងពីរត្រូវតែរិះរកមធ្យោបាយទប់ស្កាត់ជាបន្ទាន់ បើយើងនៅតែបណ្ដែតបណ្ដោយតទៅទៀតដោយគ្មានដំណោះស្រាយអ្វីសោះនោះ វានឹងបង្កឲ្យមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរដល់សេចក្ដីសុខ សុភមង្គលផ្លូវកាយផ្លូវចិត្តមនុស្ស ព្រមទាំងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ក្រុមគ្រួសារ និងសង្គមជាតិទាំងមូល ។ ហេតុនេះនៅក្នុងរយៈពេលបីថ្ងៃខាងមុខនេះ ភាគីទាំងពីរនឹងមានការពិភាក្សារវាងគណៈប្រតិភូចិន និងគណៈប្រតិភូកម្ពុជា ស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ហើយខ្ញុំសង្ឃឹមថា នឹងមានការបញ្ចប់ដោយមានការឯកភាពគ្នាលើចំណុចដែលនៅសេសសល់មួយចំនួនកាលពីប្រជុំលើកទីមួយនៅណាននាង នៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅក្នុងដំណើរទស្សនកិច្ចអន្តរក្រសួង គណៈប្រតិភូប្រទេសទាំងពីរនឹងមានការពិភាក្សាផងដែរលើសេចក្ដីព្រាងផែនការសកម្មភាព និងនីតិវិធីមួយចំនួន ដើម្បីធ្វើការការពារជនមាតុភូមិនិវត្តន៍ដែលបានរងគ្រោះមកប្រទេសដើមកំណើតវិញ ។ លោកជំទាវបានជូនពរឲ្យកិច្ចប្រជុំពិភាក្សាដំណើរការបានដោយរលូនតាមការគ្រោងទុក ហើយសូមជូនពរឲ្យគណៈប្រតិភូទាំងអស់មានសេចក្ដីសុខគ្រប់ប្រការ និងទទួលបានជោគជ័យនៅក្នុងជំនួបកិច្ចប្រជុំនេះផងដែរ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សូមបើកកិច្ចប្រជុំពិភាក្សាលម្អិតចាប់ពីពេលនេះទៅ!

**លោក ឆេន ស៊ីគូ** អគ្គនាយករង ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន ជាប្រធានគណៈប្រតិភូចិន បានថ្លែងសុន្ទរកថានៅក្នុងកម្មវិធីប្រជុំពិភាក្សាទ្វេភាគីកម្ពុជា-ចិនថា៖

លោកមានកិត្តិយសយ៉ាងខ្លាំង ដោយបានចូលរួមប្រជុំពិភាក្សាពិគ្រោះយោបល់នៅក្នុងការងារបង្ក្រាបការជួញដូរមនុស្ស ដែលបានប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសយើងទាំងពីរ ដែលមានបទល្មើសកើនឡើងជាលំដាប់ ហើយខាងប៉ូលិសបាននិងកំពុងធ្វើការបង្ក្រាប ។ រដ្ឋាភិបាលប្រទេសទាំងពីរត្រូវបន្តយកចិត្តទុកដាក់ ហើយរដ្ឋាភិបាលប្រទេសចិនបានធ្វើការផ្សព្វផ្សាយអំពីការងារបង្ក្រាបការជួញដូរមនុស្ស និងបង្កើតច្បាប់ចំនួនពីរ ដោយដាក់បទបញ្ជាឲ្យរដ្ឋាភិបាលធ្វើការបង្ក្រាប ហើយទទួលបានលទ្ធផលល្អប្រសើរ ។ ប្រទេសចិននិងប្រទេសកម្ពុជាធ្លាប់ជាបងប្អូនល្អ មានទំនាក់ទំនងដៃគូល្អជាមួយគ្នាតាំងពីយូរលង់ណាស់មកហើយ ទន្ទឹមនឹងមានការរីកចម្រើន និងមានការផ្លាស់ប្ដូររវាងប្រទេសទាំងពីរ បទល្មើសជាច្រើនក៏មានការកើនឡើង ដែលខាងប៉ូលិសមិនទាន់ធ្វើការបង្ក្រាបបទល្មើសតាមការបង្គាប់បញ្ជាពីថ្នាក់លើ ហេតុដូច្នេះថ្នាក់ដឹកនាំប្រទេសទាំងពីរដែលមាន **សម្ដេចក្រឡាហោម** និង **ប្រធានក្រុមប្រឹក្សារដ្ឋចិន** ត្រូវតែរក្សាស្ថិរភាព និងពង្រឹងកិច្ចសហប្រតិបត្តិការផ្លាស់ប្ដូរព័ត៌មានទាក់ទងនឹងការជួញដូរមនុស្សឆ្លងដែនឲ្យទទួលបានលទ្ធផលជាក់ស្ដែង ។ យោងតាមស្ថិតិពីភាគីចិនបានឲ្យដឹងថា ការជួញដូរស្ត្រីខ្មែរបានកើតមានឡើងនៅប្រទេសចិន ហើយស្ថាប័នប៉ូលិសប្រទេសទាំងពីរបានធ្វើការបង្ក្រាប

ឥតឈប់ឈរ ។ រដ្ឋាភិបាលប្រទេសចិនធ្លាប់បានចុះហត្ថលេខាជាមួយបណ្ដាប្រទេសផ្សេងៗដូចជា វៀតណាម មីយ៉ាន់ម៉ា និងឡាវ កាលពីឆ្នាំទៅ ។ រដ្ឋាភិបាលចិនបានអញ្ជើញភាគីកម្ពុជាទៅទស្សនកិច្ចប្រទេសចិន ដើម្បីពិគ្រោះពិភាក្សាលម្អិត ហើយលើកទី២បានរៀបចំធ្វើឡើងនៅខេត្តសៀមរាប ដើម្បីកំណត់កិច្ចព្រមព្រៀងទ្វេភាគីតាមសំណើភាគីកម្ពុជា ។ លោកមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា កិច្ចប្រជុំនៅទីនេះដែលមានភាគីទាំងពីរនឹងមានការឯកភាពគ្នា ដោយយើងទទួលបាននូវជោគជ័យនៅក្នុងភារកិច្ច ។

កិច្ចប្រជុំពិភាក្សាចាប់ផ្ដើមដំណើរការដោយលើកយករបៀបវារៈចំនួនបីះ

១. ប្រជុំពិភាក្សាលើខ្លឹមសារកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ចិន ស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

២. ប្រជុំពិភាក្សាកិច្ចដំណើរការបទដ្ឋានការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះ ។

៣. ប្រជុំពិភាក្សាលើសេចក្ដីព្រាងផែនការសកម្មភាពរួម ក្រោមកិច្ចព្រមព្រៀងទ្វេភាគី ។

យើងនឹងធ្វើការពិនិត្យពិភាក្សាលើទិដ្ឋភាពច្បាប់ទូទៅ ការឲ្យនិយមន័យលើឃ្លាប្រយោគនៃមាត្រានីមួយៗ មានការកែប្រែពាក្យពេចន៍ខ្លះឲ្យបានត្រឹមត្រូវរវាងក្រុមការងារបច្ចេកទេសទាំងពីរ ហើយត្រូវមានការបញ្ជាក់អត្ថន័យបន្ថែមឲ្យកាន់តែច្បាស់ទៀតក្នុងកិច្ចព្រមព្រៀងនេះ ។ យើងនឹងធ្វើការពិភាក្សាលើឃ្លានីមួយៗមានការឯកភាពគ្នាឬអត់ ត្រូវបំពេញខ្លឹមសារឲ្យបានសមរម្យនៅមាត្រា៤ ៥ ៦ និង៧ ហើយឯកសារទាំងនេះ ត្រូវមានការឯកភាពពីស្ថាប័នប៉ូលិស ក្រសួងការបរទេសប្រទេសទាំងពីរ ហើយធ្វើការ highlight លើមាត្រាទាំងនោះ ។

យើងត្រូវមានការឯកភាពគ្នាលើកិច្ចព្រមព្រៀង ស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ហើយមានស្ថាប័នពាក់ព័ន្ធរបស់ភាគីចិនបានចូលរួមផងដែរ ដើម្បីនឹងធ្វើការពិភាក្សាលើការងារ (POA) ដោយពិនិត្យលើតារាងទាំងពីរដោយមាន comment ត្រូវមានការពិភាក្សាលើការងារឲ្យបានចប់សព្វគ្រប់លើសេចក្ដីព្រាងនេះឲ្យបានចប់ និងមានការចុះហត្ថលេខារវាងរដ្ឋាភិបាលប្រទេសទាំងពីរ ហើយកិច្ចព្រមព្រៀងនេះតម្រូវឲ្យមានការព្រមព្រៀង ដោយមានកិច្ចពិភាក្សាលម្អិតរវាងក្រុមបច្ចេកទេសនៃប្រទេសទាំងពីរ ហើយរដ្ឋាភិបាលប្រទេសចិនធ្លាប់បានធ្វើកិច្ចការនេះជាមួយប្រទេសមួយចំនួនមាន វៀតណាម មីយ៉ាន់ម៉ា ឡាវ ហើយនិងជាមួយប្រទេសកម្ពុជាផងដែរ ដោយមានកិច្ចសហប្រតិបត្តិការល្អជាមួយបបណ្ដាប្រទេសទាំងនោះ ។

**លោក ឆេន ស៊ីគូ** បានលើកឡើងថា កិច្ចពិភាក្សារវាងប្រទេសទាំងពីរអាចឆ្លើយឆ្លងតាមរយៈសារអេឡិចត្រូនិច( e-mail )ទៅវិញទៅមក រាល់ឯកសារពាក់ព័ន្ធទាំងនេះត្រូវមានការពិភាក្សាលម្អិតបន្ថែមទៀតពីការរៀបចំធ្វើផែនការសកម្មភាពបន្តនៅឆ្នាំក្រោយទៀត ហើយយើងមានឯកសារត្រៀមទុកដូចជា ផែនការសកម្មភាពសម្រាប់ចុះហត្ថលេខាដោយបែងចែកជាចំនួនឆ្នាំ ដើម្បីបញ្ចប់នៅដើមឆ្នាំក្រោយគឺនៅចុងឆ្នាំ២០១៦ ខែវិច្ឆិកា ដើម្បីបញ្ចប់ការងារទាំងអស់នេះជាមួយរដ្ឋាភិបាលមានចំនួន ០៦តំបន់គោលដៅ ដែលបានធ្វើកិច្ចសហប្រតិបត្តិការ ។ យើងមានការផ្លាស់ប្ដូររបាយការណ៍ Progress Report ពីគ្នាទៅវិញទៅមក ដោយមានការជួបប្រជុំតាមសារអេឡិចត្រូនិច ហើយយើងនឹងធ្វើ Make progress next year ដើម្បីធ្វើការកែតម្រូវជំនួសកិច្ចការនេះ វាមិនមានការលំបាកទេ ។ យើងសង្ឃឹមថា កិច្ចសហប្រតិបត្តិការមានភាពល្អប្រសើរមានការផ្លាស់ប្ដូរបទពិសោធន៍ពីគ្នា និងបន្ទាប់ពីមានកិច្ចប្រជុំពិភាក្សាលើឯកសារកិច្ចព្រមព្រៀងចុងក្រោយនេះ យើងនឹងដាក់ឯកសារនេះជូនប្រមុខរាជរដ្ឋាភិបាលនៃប្រទេសធ្វើការពិនិត្យសម្រេច ។ ដោយមានការយល់ព្រមលើ Activity នៅក្នុងតារាង សូមបញ្ជាក់ពី Identify Letter ដោយមានការពិភាក្សា Activity key បន្ថែមទៀតនៅដើមឆ្នាំ២០១៧ ។ មុននឹងមានការចុះហត្ថលេខាគួរតែមានការបន្ថែម ដកយកខ្លឹមសារ ឬលុបចោល មុននឹងចុះកិច្ចព្រមព្រៀងទ្វេភាគី ដោយមានក្រុមការងារប្រទេសទាំងពីរធ្វើការងារពិភាក្សាលម្អិតលើ Plan Action Draft ជាមុនសិន ។

នៅពេលបញ្ចប់កម្មវិធីកិច្ចប្រជុំពិភាក្សាការងារលម្អិតជាមួយប្រតិភូចិន **លោកជំទាវ ជូ ម៉ុនអេង** មានមតិស្វាគមន៍គណៈប្រតិភូចិន ដែលបានខិតខំប្រជុំពិភាក្សារហូតទទួលបានលទ្ធផលល្អ ហើយយើងបានធ្វើការឯកភាពគ្នាលើកំណត់ហេតុប្រជុំកិច្ចព្រមព្រៀងពីការពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដោយយើងបានរៀបចំធ្វើ ឡើងជាពីរច្បាប់ថតចម្លង គឺមួយច្បាប់ជាភាសាខ្មែរ និងមួយច្បាប់ជាភាសាចិន ។ សម្រាប់ជាភាសាចិន សូមប្រគល់ទៅឲ្យភាគីប្រទេសចិន ហើយមួយច្បាប់ទៀតប្រគល់ឲ្យភាគីកម្ពុជា សម្រាប់ធ្វើការចុះហត្ថលេខាលើកំណត់ហេតុប្រជុំលើរបៀបវារៈដែលបានលើកឡើង ។ យើងនឹងធ្វើការថតចម្លងកិច្ចព្រមព្រៀងនេះទៅកាន់គណៈប្រតិភូទាំងពីរដើម្បីធ្វើការចុះហត្ថលេខា រាល់ភាគីនីមួយៗនឹងទទួលបានមួយច្បាប់ដែលបានបែងចែកដោយភាគីកម្ពុជាសម្រាប់ ចុះហត្ថលេខាលើកំណត់ហេតុអង្គប្រជុំចំនួនពីរថ្ងៃកន្លងមកនេះ ។

សម្រាប់ភាគីទាំងពីរបានឯកភាពលើចំណុច៣ សំខាន់ដូចខាងក្រោមនេះ៖

1) បានពិនិត្យ បញ្ចប់ និងរៀបចំឱ្យមានសេចក្តីព្រាងនៃកិច្ចព្រមព្រៀងជាបីភាសា៖ ចិន ខ្មែរ និងអង់គ្លេស ដែលមានតម្លៃស្មើគ្នា
2) ព្រមព្រៀងគ្នាលើសកម្មភាពដែលបានស្នើឡើងចំនួនប្រាំសម្រាប់ឆ្នាំ២០១៧ដែលរួមមាន៖
   - ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិនឱ្យហួសពីឆ្នាំ២០១៦
   - រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំលើកទី១ នៅប្រទេសចិន ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ (ពិនិត្យបញ្ចប់ផែនការសកម្មភាពឆ្នាំ២០១៧)
   - តែងតាំងជនបង្គោលសម្រាប់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការទ្វេភាគី
   - ធ្វើកិច្ចប្រតិបត្តិការអនុវត្តច្បាប់រួមគ្នា ពីខែឧសភាដល់ ខែកក្កដា ឆ្នាំ២០១៧
   - រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការពង្រឹងការអនុវត្តច្បាប់រួមគ្នា ធ្វើនៅប្រទេសចិន
3) ឯកភាពពិនិត្យឡើងវិញនូវសេចក្តីព្រាងនីតិវិធី ប្រតិបត្តិបទដ្ឋាន សម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំនៅត្រីមាសទី១ ឆ្នាំ២០១៧ ។

ភ្នំពេញ ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ២០១៦

**អ្នកកត់ត្រា**

kamil

គោរពជូន លោកជំទាវ
អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។
ភ្នំពេញ ថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០១៦
**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី **គង់_ពុទ្ធី**

19/09/2016

ជូ_ម៉ុនអេង